# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០៤៣/២១..........ក.ប/ស.ណ.ន.ខ.ល

## សេចក្តីណែនាំ

## ស្តីពី

## ការបើកផ្តល់ប្រាក់ឈ្នួលដើមខែមេសា និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដល់កម្មករនិយោជិតក្នុងអំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

យោងតាមច្បាប់ស្តីពីការងារ ការផ្អាកសកម្មភាពអាជីវកម្មរបស់រោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដោយសារការអនុវត្តវិធានការបិទខ្ទប់ជាបណ្តោះអាសន្ននូវភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល នាំឱ្យមានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។ ដើម្បីធានាផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិតនៅក្នុងអំឡុងពេលនៃការបិទខ្ទប់នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស សិប្បកម្ម និងក្រុមហ៊ុន ដែលត្រូវផ្អាកសកម្មភាពអាជីវកម្មក្នុងអំឡុងពេលបិទខ្ទប់ដូចខាងក្រោម៖

១. ត្រូវរក្សាប៉ុស្តិ៍ការងារ និងរក្សាអតីតភាពការងារជូនកម្មករនិយោជិតរបស់ខ្លួនក្នុងអំឡុងពេលបិទខ្ទប់នេះ។

២. ត្រូវបើកផ្តល់ប្រាក់ឈ្នួលដើមខែមេសា (ប្រាក់ឈ្នួលសម្រាប់ថ្ងៃទី០១ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១) ជូនកម្មករនិយោជិតរបស់ខ្លួន ប្រសិនជាមិនទាន់បានបើកផ្តល់នាពេលកន្លងមក។ ការបើកផ្តល់នេះសូមធ្វើនៅក្រោយពេលចប់វិធានការបិទខ្ទប់។

៣. ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជូនដល់កម្មករនិយោជិតរបស់ខ្លួនទៅតាមលទ្ធភាព ដោយផ្អែកលើស្មារតីមនុស្សធម៌ សាមគ្គីភាព និងទំនួលខុសត្រូវសង្គមនៅក្នុងគ្រាលំបាករួមនេះ។ ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមនេះក៏សូមធ្វើនៅក្រោយពេលចប់វិធានការបិទខ្ទប់។

ដើម្បីសម្រួលដល់ការលំបាករបស់បងប្អូនកម្មករនិយោជិត ដែលកំពុងរស់នៅជាក់ស្តែងនៅតាមបន្ទប់ជួលនៃតំបន់បិទខ្ទប់ រាជរដ្ឋាភិបាលបាននិងកំពុងផ្តល់ជំនួយសង្គមផ្សេងៗ តាមរយៈរដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្តាលផងដែរ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស សិប្បកម្ម ក្រុមហ៊ុន និងបងប្អូនកម្មករនិយោជិតទាំងអស់នឹងអនុវត្តសេចក្តីណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវ និងយោគយល់គ្នា។

ថ្ងៃ ចន្ទ ៨កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មការជាតិ ត.ប.ខ
- រដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្តាល
  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាព និងមន្ទីរនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  *"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"*